The Bible Story in Honor-Shame (Khmer)

# រឿងក្នុងព្រះគម្ពីរអំពីកិត្តិយស និងភាពអាម៉ាស់

ព្រះជាម្ចាស់ទ្រង់គង់នៅអស់កល្បជានិច្ចពេញដោយសិរីរុងរឿង និងកិត្តិយស។ ទ្រង់ជាមហាក្រត្រគួរអោយ គោរព ជាបិតាដែលផ្គត់ផ្គង់ដល់គ្រួសារទាំងមូល។ ទ្រង់បរិសុទ្ធ ស្មោះត្រង់ និងពោរពេញដោយសិរីល្អ - ជាសារៈសំខាន់ និងជាប្រភពនៃកិត្តិយសទាំងអស់។

ដើម្បីបង្ហាញពីសិរីរុងរឿងទ្រង់ព្រះអង្គបានបង្កើតពិភពលោកនេះព្រមទាំងមានបន្ទូលអោយរបស់ទាំងអស់មានជីវិតឡើង។ ព្រះជាម្ចាស់បានបង្កើតអ័ដាម និងអេវ៉ាពីដីមកហើយអោយពួកគេមានកិត្តិយស និងសិរីល្អ។ ពួកគេមានអំណាចគ្រប់គ្រងលើរបស់ទាំងអស់ដែលព្រះបានបង្កើតមកស្របតាមព្រះបន្ទូលទ្រង់។ ក្នុងនាមជាកូនរបស់ព្រះពួកគេរស់នៅក្នុងនាមព្រះអង្គ។ អ័ដាម និងអេវ៉ារីករាយជាមួយនឹងអត្តសញ្ញាណពេញដោយកិត្តិយសពីព្រះជាម្ចាស់។ ពួកគេរស់នៅទាំងខ្លួនអាក្រាតហើយមិនមានការខ្មាស់អៀនសោះឡើយ។

ប៉ុន្តែអ័ដាម និងអេវ៉ាមិនស្មោះត្រង់ជាមួយព្រះជាម្ចាស់។ ពួកគេបានបោះបង់ចោលកិត្តិយសរបស់ព្រះជាម្ចាស់ដោយសារពួកគេដេញតាមកិត្តិយសរបស់ខ្លួនឯង។ ការមិនស្មោះត្រង់ចំពោះព្រះនេះបង្កអោយកើតមានភាពអាម៉ាស់ ហេតុដូច្នេះបានជាគេរត់ពួនហើយបិទបាំងខ្លួនឯង។ ព្រះជាម្ចាស់បាត់បង់កិត្តិយសដោយសារតែអ័ដាម និងអេវ៉ាបាននាំនូវភាពអាម៉ាស់នេះដល់មនុស្សគ្រប់គ្នា ហេតុនេះបានជាព្រះជាម្ចាស់បណ្តេញគេចេញដើម្បីរក្សាកិត្តិយស់ទ្រង់។

ក្នុងនាមជាកូនចៅរបស់អ័ដាមគឺយើងទទួលបាននូវភាពអាម៉ាស់របស់គាត់ដែរ។ ការប្រមាថនិងចិត្តដែលមិនស្មោះត្រង់របស់យើងបង្កើតនូវភាពអាម៉ាស់កាន់តែខ្លាំងឡើង។ ភាពអាម៉ាស់នេះបង្កើតនូវអត្តសញ្ញាណ និងអត្តចរិករបស់យើង។ អំពើបាប (ឧទាហរណ៍ៈ ការរំលោភបំពាន កំហឹង និយាយដើម អួតអាងរើសអើងជាតិសាសន៍ ហឹង្សា សង្គ្រាម។) ភាគច្រើនគឺជាការប៉ុនប៉ងមិនត្រឹមត្រូវក្នុងគោលបំណង ដើម្បីបិទបាំងភាពអាម៉ាស់ និងប្រឌិតអោយមានការគោរព។ យើងបង្កើតនូវអត្តសញ្ញាណមិនត្រឹមត្រូវហើយតែងតែធ្វើអោយកើតមានភាពអាម៉ាស់ដល់អ្នកដ៏ទៃ ឬអួតអាងវាយឫកថាយើងល្អជាងគេនៅក្នុងក្រុមរបស់យើង។ ដោយសារតែបាត់បង់មុខមាត់ខាងវិញ្ញាណ គ្រួសារ ឈ្មោះ និងឋានៈរបស់យើង ជីវិតរបស់យើងខិតខំជានិច្ច

ដើម្បីសាងនូវកិត្តិយសក្លែងក្លាយ។ ដូចជារឿងរ៉ាវដែលបង្ហាញនៅក្នុងរឿងប៉បបាបិលមនុស្សគ្រប់គ្នាចាប់ផ្តើមស្វែករកការលើកខ្លួនឯងឡើង និងបង្កើតអោយមានឈ្មោះខ្លួនឯង។ សេចក្តីអាម៉ាស់របស់យើងបង្ករអោយកើតមានការអាប់ឱនកិត្តិយស និងការមិនគោរពព្រះជាម្ចាស់។

ព្រះក៏បានរៀបចំផែនការដើម្បីស្រោចស្រង់មនុស្សអោយទទួលបានកិត្តិយសឡើងវិញ។ ទ្រង់បានចងសម្ព័ន្ធមេត្រីដើម្បីផ្តល់កិត្តិយសដល់លោកអ័ប្រាហាំថានឹងអោយគាត់មានឈ្មោះល្បី មានទឹកដី ព្រះពរ ជាតិសាសន៍ និងកូនចៅជាច្រើន។ ក្នុងនាមជាជាតិសាសន៍ដ៏អស្ចារ្យក្រុមគ្រួសារលោកអ័ប្រាហាំនឹងក្លាយទៅជាឧបករណ៍របស់ព្រះដើម្បីផ្តល់ពរ - ឬការគោរព - ដល់គ្រប់ជាតិសាសន៍។ ខណៈពេលដែលកូនចៅរបស់លោកអ័ប្រាហាំរងទុក្ខវេទនាក្លាយជាទាសករនៅក្នុងប្រទេសអេស៊ីបព្រះជាម្ចាស់បានរំដោះពួកគេឲ្យរួចផុតពីចំណងនៃសេចក្តីអាម៉ាស់។ ជនជាតិអ៊ីស្រាអែលបានក្លាយទៅជាប្រជាជាតិដ៏អស្ចារ្យ គឺជាប្រជាជាតិដ៏ជាទីស្រឡាញ់របស់ព្រះ និងជាទីសព្វព្រះទ័យចំពោះទ្រង់។

ព្រះជាម្ចាស់បានតាំងសម្ព័ន្ធមេត្រីពិសេសដើម្បីផ្តល់កិត្តិយសដល់ជនជាតិអ៊ីស្រាអែលបើពួកគេគោរពព្រះអង្គ មិនប្រួលប្រែព្រមទាំងស្តាប់តាមការប្រៀនប្រដៅរបស់ទ្រង់។ បទបញ្ជានៃការប្រៀនប្រដៅសម្អាតនូវភាពកខ្វក់របស់  ជនជាតិអ៊ីស្រាអែល និងអោយពួកគេមានសហគមន៍ជាថ្មីឡើងវិញ។ ថ្វីដ្បិតតែព្រះជាម្ចាស់មានបំណងព្រះទ័យ ចង់អោយការតាំងសញ្ញារបស់ទ្រង់នាំមកនូវកិត្តិយស តែច្រើនដងជនជាតិអ៊ីស្រាអែលមិនស្មោះត្រង់ថែមទាំងបង្ខូចដល់ ព្រះនាមព្រះជាម្ចាស់ក្នុងចំណោមជាតិសាសន៍ទាំងឡាយទៀតផង។ ពេលបែរទៅរកព្រះផ្សេងពួកគេតែងតែបំផ្លាញ ព្រះនាមទ្រង់ដូចជាប្តីប្រពន្ធមិនចុះសម្រុងគ្នា។ ជនជាតិអ៊ីស្រាអែលជាពូជជ្រើសរើសដែលប្រសើរជាងជាតិសាសន៍ដ៏ទៃ - ជាក្រុមសុចរិត។ ពួកគេជឿថាសាសន៍ដ៏ទៃអន់ និងមិនសមក្លាយជាសមាជិកក្រុមគ្រួសារព្រះឡើយ។ អ៊ីស្រាអែលគឺដូចជាអ័ដាមត្រូវបានជ្រើសរើសសម្រាប់អោយទទួលបាននូវកិត្តិយសប៉ុន្តែត្រូវបញ្ចប់ទៅវិញដោយការនិរទេសក្នុងភាពអាម៉ាស់។ ទោះបីជារឿងរ៉ាវរបស់អ៊ីស្រាអែលបញ្ចប់ទៅដោយបង្ករអោយមានភាពអាម៉ាស់ដល់ជាតិសាសន៍ តែសេចក្តីសន្យារបស់ព្រះដើម្បីលើកពួកគេឡើង (ឧទាហរណ៍ៈ នាងរស់ ដាវីឌ ដានីយ៉ែល និងនាងអេសធើ) ប្រាប់អោយដឹងជាមុននូវប្រឲ្យលក្នុងការជួយសង្គ្រោះគ្រួសារមនុស្សលោកចេញពីភាពអាម៉ាស់ និងដើម្បីអោយ

គេទទួលបានកិត្តិយសឡើងវិញ។

ទោះបីជាទ្រង់បានទទួលនូវសិរីល្អនៅអស់កល្បជានិច្ច និងមានកិត្តិយសជាកូនព្រះនៅស្ថានសួគ៌ក៏ដោយព្រះយេស៊ូបានក្លាយជាមនុស្សទន់ទាបដើម្បីសង្គ្រោះមនុស្សចេញពីភាពអាម៉ាស់។ អព្ភូតហេតុនៃការព្យាបាលដ៏អស្ចារ្យរបស់ទ្រង់និងការស្តារការប្រកបគ្នាឡើងវិញព្រមទាំងផ្តល់កិត្តិយសដល់មនុស្សដែលបាត់បង់ឱកាស។ ព្រះយេស៊ូទ្រង់ពោរពេញដោយកិត្តិយសសម្រាប់អស់អ្នកណាដែលប៉ះពាល់ទ្រង់នឹងបានស្អាតបរិសុទ្ធនិងត្រូវបានទទួលយក។ សេចក្តីបង្រៀនរបស់ទ្រង់ប្រកាសប្រាប់ពីសេចក្តីពិតនិងការផ្តល់កិត្តិយសមកពីព្រះជាម្ចាស់ដ៏នៅអស់កល្បជានិច្ច។

ទ្រង់ស្រឡាញ់និងទទួលយកមនុស្សគ្រប់គ្នាដោយមិនគិតអំពីកេរ្តិ៍ឈ្មោះឡើយព្រះយេស៊ូកាត់បន្ថយតម្លៃខុសឆ្គងចំពោះកិត្តិយសដែលសង្គមផ្តល់អោយនិងអោយមនុស្សមានកិត្តិយសពិតពីព្រះទៅដល់មនុស្សគ្រប់គ្នា។ ជីវិតព្រះយេស៊ូទ្រង់រស់នៅដោយការគោរពយ៉ាងពេញលេញទៅកាន់ព្រះជាម្ចាស់។

ប៉ុន្តែព័ន្ធកិច្ចរបស់ព្រះយេស៊ូបានធ្វើអោយមានការគំរាមកំហែងដល់អ្នកដឹកនាំដែលចាក់ឬសនៅផែនដីនេះ។ ដូច្នេះហើយបានជាពួកគេឆ្លើយតបមកវិញដោយការធ្វើអោយមានភាពអាម៉ាស់ដល់ទ្រង់ជាសាធារណៈ និងគួរអោយភ័យខ្លាច។ ព្រះយេស៊ូត្រូវបានពួកគេចាប់ខ្លួន ដោះសម្លៀកបំពាក់ចេញ ចំអក វាយស្តោះទឹកមាត់ដាក់ ដំដែកគោល និងត្រូវព្យួរដោយខ្លួនអាក្រាតនៅលើឈើឆ្កាងចំពោះមុខមនុស្សទាំងអស់។ ទ្រង់រងទុក្ខទោសនូវរាល់ក្តីអាម៉ាស់ទាំងអស់ដោយភាពស្មោះត្រង់ និងបានបំបាក់អំណាចរបស់វាចេញ។ ឈើឆ្កាងបានស្តារកិត្តិយសព្រះជាម្ចាស់ និងដកនូវភាពអាម៉ាស់របស់យើងចេញ។ ការឈមមុខត្រូវបានស្តារឡើងវិញ។

បន្ទាប់មកព្រះជាម្ចាស់បានអនុញ្ញាតិអោយព្រះយេស៊ូសុគតដោយរងនូវក្តីអាម៉ាស់នៅទីសាធារណៈរួចប្រោសទ្រង់អោយមានព្រះជន្មរស់ឡើងវិញពេញដោយសិរីរុងរឿង។ ឥឡូវនេះព្រះយេស៊ូគង់នៅខាងស្តាំដៃនៃព្រះបិតាខ្ពស់លើអស់ទាំងនាមផង។ ចំណែកអ័ដាម និងជនជាតិអ៊ីស្រាអែលបានបរាជ័យ ព្រះយេស៊ូទទួលបានជោគជ័យក្នុងនិស្ស័យជាមនុស្សរបស់ទ្រង់ដោយជីវិតរបស់ទ្រង់គោរពព្រះជាម្ចាស់ និងក្រុមគ្រួសាររបស់មនុស្សផង។

អស់អ្នកដែលទុកចិត្តដល់ព្រះយេស៊ូនឹងទទួលបាននូវឋានៈថ្មី។ ក្តីអាម៉ាស់របស់គេនឹងត្រូវបានគ្របបាំង ហើយកិត្តិយសរបស់គេនឹងត្រូវបានស្តារឡើងវិញ។ មនុស្សគ្រប់រូបត្រូវបោះបង់ចោលការប្រកួតក្នុឧបាយកលសង្គម ការក៏សាងកេរ្តិ៍ឈ្មោះ និងមុខមាត់ខ្លួនឯងតែត្រូវទុកចិត្តទាំងស្រុងលើព្រះយេស៊ូសម្រាប់កេរ្តិ៍ឈ្មោះថ្មី។ ការក្លាយខ្លួនជាសមាជិកថ្មីរបស់ព្រះជាម្ចាស់មិនផ្អែកលើជាតិសាសន៍ កិត្តិយស ឬភាពបរិសុទ្ធក្នុងសាសនា ប៉ុន្តែត្រូវមានភក្តីភាពចំពោះព្រះមេស៊ីដែលបានជាប់ឆ្កាងសម្រាប់អ្នកវិញ។ ព្រះជាម្ចាស់បានផ្លាស់ប្តូរស្ថានភាពចាស់របស់យើងដែលមិនបរិសុទ្ធ គ្មានតម្លៃ ជាមនុស្សមានឋានៈទាបថោកសក្តិសម និងកូនៗដែលមានកិត្តិយស។ អស់អ្នកដែលដើរតាមព្រះគ្រីស្តទៅកាន់ឈើឆ្កាងនៃភាពអាម៉ាស់ក៏នឹងដើរតាមទ្រង់ទៅកាន់សិរីរុងរឿងនៃការរស់ឡើងវិញជាមួយទ្រង់ដែរ។

ការស្វាគមន៍ចូលមកកាន់គ្រួសារព្រះធ្វើអោយមនុស្សចេះស្វាគមន៍គ្នា និងទទួលគ្នាទៅវិញទៅមកក្នុងក្រុមមួយទៀត។ គ្រីស្ទានអាចផ្តល់ការគោរពដល់មនុស្សជាច្រើនទៀត ព្រមទាំងថ្វាយសិរីល្អដល់ព្រះ ដោយសារពួកគេបានទទួលនូវកិត្តិយលនៃការគោរពដ៏នៅអស់កល្ប និងអំណាចពីព្រះវិញ្ញាណ។ នៅពេលព្រះយេស៊ូយាងត្រលប់មកវិញ អ្នកមិនជឿនឹងត្រូវដកហូតកិត្តិយស និងបោះទៅក្នុងភាពអាម៉ាស់ជារៀងរហូត ខណៈពេលដែលអ្នកជឿនឹងទទួលបានមកុដកិត្តិយសនៅអស់កល្បជានិច្ចដោយសារសិរីរុងរឿងរបស់ព្រះបានបំពេញរាល់ការបង្កើតទាំងអស់។